ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គិសនីកម្ពុជា

លេខ : ៧២០ សណន.គគ.គម

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៣

# សេចក្តីណែនាំ

អគ្គិសនីកម្ពុជា បាននឹងកំពុងខិតខំបំពេញភារកិច្ច ផ្តល់សេវាផ្គត់ផ្គង់ថាមពលអគ្គិសនីជូនអតិថិជនគ្រប់ប្រភេទរបស់ខ្លួនបានកាន់តែប្រសើរជាលំដាប់។ ទោះជាយ៉ាងនេះក្តី បាតុភាពអសកម្មមួយចំនួននៅមានសេសសល់ ផ្តល់ការថ្នាំងថ្នាក់ដល់អតិថិជនមួយចំនួនលើការយកថ្លៃសេវាបន្តចរន្តលើសពីការកំណត់របស់អាជ្ញាធរអគ្គិសនីកម្ពុជា ។

ដើម្បីលុបបំបាត់ភាពអសកម្មនេះ អគ្គិសនីកម្ពុជា សូមណែនាំ សាខាអគ្គិសនីទាំងអស់ ចំណុះអគ្គិសនីកម្ពុជា ដូចខាងក្រោម:

១. រាល់អតិថិជន ឬ និតិបុគ្គល ដែលស្នើសុំបន្តចរន្តអគ្គិសនី ឬ តម្លើងត្រូវចុះហត្ថលេខា ឬ ផ្តិតមេដៃ ដោយផ្ទាល់នៅលើពាក្យស្នើសុំបន្តចរន្តអគ្គិសនី និង នៅលើឯកសារពាក់ព័ន្ធផ្សេងទៀត ដែលចែកជូនដោយឥតគិតថ្លៃ ។

២. តម្លៃសេវាបន្តចរន្ត និង ប្រាក់កក់ លើការសុំបន្តចរន្តអគ្គិសនី ពីបណ្តាញសាធារណៈ ត្រូវអនុវត្តទៅតាមការកំណត់របស់អាជ្ញាធរអគ្គិសនីកម្ពុជា ដូចដែលបានបញ្ជាក់ក្នុងតារាងនៃពាក្យស្នើសុំបន្តចរន្តអគ្គិសនី ។

៣. រយៈពេលផ្តល់សេវាបន្តចរន្ត ត្រូវអនុវត្តទៅតាមការកំណត់របស់អាជ្ញាធរអគ្គិសនីកម្ពុជា គឺ មិនលើសពី:

- **១៥ថ្ងៃ សម្រាប់អតិថិជនទំហំចាប់ពី** 1ph × 5A **ដល់** 1ph × 63A
- **៤៥ថ្ងៃ សម្រាប់អតិថិជនទំហំចាប់ពី** 3ph × 20A **ដល់** 3ph × 100A

៤. ករណីមាននិយោជិតអគ្គិសនីកម្ពុជា អនុវត្តខុសពីសេចក្តីណែនាំខាងលើនេះ និយោជិតនោះនឹងត្រូវទទួលវិន័យរដ្ឋបាល ដោយត្រូវលុបឈ្មោះចេញពីក្របខ័ណ្ឌអគ្គិសនីកម្ពុជា ហើយនឹងត្រូវផ្សព្វផ្សាយករណីនីមួយៗ តាមទំព័រសារព័ត៌មានផង ។

អគ្គិសនីកម្ពុជា សង្ឃឹមយ៉ាងមុតមាំថា ថ្នាក់ដឹកនាំ និយោជិតកម្មករនៃអគ្គិសនីកម្ពុជាទាំងអស់នឹងចូលរួមប្រតិបត្តិ ការណែនាំនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ និងឈរលើស្មារតីទទួលខុសត្រូវ ។

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា**
**ទទួលបន្ទុកជាអគ្គនាយកអគ្គិសនីកម្ពុជា**

ELECTRICITE DU CAMBODGE

**កែវ រតនៈ**